**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ២៣ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការរៀបចំ និងការប្រព្រឹត្តិទៅរបស់លេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិ សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០០១ ដែលប្រកាស ឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២០៨/១៤២៩ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៨ ស្តីពីការបង្កើតគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- យោងតាមសំណើរបស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

## សម្រេច

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ត្រូវបង្កើតលេខាធិការដ្ឋានមួយ ដើម្បីធ្វើជាសេនាធិការឱ្យគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដែលហៅកាត់ថា "លេខាធិការដ្ឋាន គ.ជ.អ.ប "។

**មាត្រា ២.-**

លេខាធិការដ្ឋាន គ.ជ.អ.ប មានទីតាំងស្ថិតនៅក្នុងទីស្តីការក្រសួងមហាផ្ទៃ។

## ជំពូកទី២
## តួនាទី ភារកិច្ច

**មាត្រា ៣.-**

លេខាធិការដ្ឋាន គ.ជ.អ.ប មានតួនាទីធ្វើជាសេនាធិការជូន គ.ជ.អ.ប ក្នុងការអនុវត្តច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និងគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ។

**មាត្រា ៤.-**

លេខាធិការដ្ឋាន គ.ជ.អ.ប មានភារកិច្ចសំខាន់ៗដូចខាងក្រោម :

- សម្របសម្រួលកិច្ចការប្រចាំថ្ងៃរបស់ គ.ជ.អ.ប ស្របតាមការណែនាំ និងការសម្រេចរបស់ គ.ជ.អ.ប
- សហការសម្របសម្រួលជាមួយអនុគណៈកម្មាធិការនៃគ.ជ.អ.ប ដៃគូអភិវឌ្ឍន៍ និងអ្នកពាក់ព័ន្ធនានាតាមការចាំបាច់ ដើម្បីរៀបចំសេចក្តីព្រាងកម្មវិធីជាតិ ផែនការសកម្មភាព លិខិតបទដ្ឋានអនុវត្តច្បាប់ និងឯកសារនានាតាមការកំណត់របស់ គ.ជ.អ.ប ដើម្បីសុំការសម្រេចពី គ.ជ.អ.ប
- ត្រៀមរៀបចំកិច្ចប្រជុំទាំងអស់របស់ គ.ជ.អ.ប
- ជួយគាំទ្រ និងផ្តល់យោបល់ដល់អនុគណៈកម្មាធិការនានានៃ គ.ជ.អ.ប
- ធ្វើការពិនិត្យសង្ខេបបូកសរុបឯកសារ របាយការណ៍លទ្ធផល នៃកិច្ចប្រជុំ អនុសាសន៍ សំណើ សំណូមពរ ដែលផ្តល់ជូនដោយអនុគណៈកម្មាធិការនានា ដោយភ្ជាប់ជាមួយអនុសាសន៍របស់ខ្លួន ដើម្បីដាក់ជូន គ.ជ.អ.ប
- ផ្សព្វផ្សាយព័ត៌មានជូនសាធារណជនអំពីកំណែទម្រង់រដ្ឋបាលថ្នាក់ក្រោមជាតិ
- សម្របសម្រួល និងរៀបចំឱ្យមានការពិគ្រោះយោបល់នានានៅថ្នាក់ក្រោមជាតិ ថ្នាក់ជាតិ និងជាមួយអន្តរជាតិ អំពីការអនុវត្តច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ស្របតាមការណែនាំរបស់ គ.ជ.អ.ប
- ធ្វើការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃជាប្រចាំលើការអនុវត្តច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និងគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ

- សម្របសម្រួលគម្រោងគាំទ្រពីដៃគូអភិវឌ្ឍន៍នានាដល់កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការតាមការណែនាំពីគ.ជ.អ.ប

- អាចធ្វើជាប្រតិបត្តិករនូវគម្រោង កម្មវិធីដែលគាំទ្រពីដៃគូអភិវឌ្ឍន៍នានា តាមការសម្របសម្រួលគ្នារវាងដៃគូអភិវឌ្ឍន៍ទាំងនោះ និងតាមការសម្រេចរបស់ គ.ជ.អ.ប

- ចូលរួមជាមួយដៃគូអភិវឌ្ឍន៍ក្នុងក្រុមការងារបច្ចេកទេសវិមជ្ឈការ និងវិសហមជ្ឈការ

- គ្រប់គ្រងថវិកា និងហិរញ្ញវត្ថុរបស់ គ.ជ.អ.ប

- បំពេញការងារផ្សេងៗទៀតតាមការកំណត់របស់ គ.ជ.អ.ប ។

**មាត្រា ៥.-**

លេខាធិការដ្ឋាន អាចទទួលបានការធ្វើប្រតិភូកម្មការងារតាមការចាំបាច់ពី គ.ជ.អ.ប ហើយគ.ជ.អ.ប ក៏អាចដកយកសិទ្ធិអំណាចដែលបានធ្វើប្រតិភូកម្មនោះមកវិញបានដែរ ។

## ជំពូកទី៣
## រចនាសម្ព័ន្ធ

**មាត្រា ៦.-**

លេខាធិការដ្ឋាន គ.ជ.អ.ប ត្រូវដឹកនាំដោយប្រធាន ០១រូប អមដោយអនុប្រធាន ០៣រូប ជាជំនួយការ ។

ប្រធានលេខាធិការដ្ឋាន ជារដ្ឋលេខាធិការ ០១រូប នៃក្រសួងមហាផ្ទៃ។

អនុប្រធានទី១ នៃលេខាធិការដ្ឋាន គឺជាអគ្គនាយករដ្ឋបាលមូលដ្ឋាននៃក្រសួងមហាផ្ទៃ។

អនុប្រធាន ០២រូបទៀត នៃលេខាធិការដ្ឋាន មានឋានៈស្មើអគ្គនាយក ។

ប្រធាន និងអនុប្រធានលេខាធិការដ្ឋាន ត្រូវតែងតាំងដោយព្រះរាជក្រឹត្យ តាមសំណើរបស់ប្រធាន គ.ជ.អ.ប ។

**មាត្រា ៧.-**

លេខាធិការដ្ឋានមានអង្គភាពចំណុះ ដូចខាងក្រោម :

- អង្គភាពគាំទ្រកម្មវិធី
- អង្គភាពគាំទ្រគោលនយោបាយ
- អង្គភាពអន្តរក្រសួង ។

អង្គភាពនីមួយៗត្រូវដឹកនាំដោយប្រធាន ០១រូប និងអនុប្រធានមួយចំនួនជាជំនួយការ ។

ប្រធានអង្គភាពមានឋានៈស្មើអគ្គនាយករង អនុប្រធានអង្គភាពមានឋានៈស្មើប្រធាននាយកដ្ឋាន ដែលត្រូវតែងតាំងឡើងដោយអនុក្រឹត្យតាមសំណើរបស់ប្រធាន គ.ជ.អ.ប ។

តួនាទី និងភារកិច្ចរបស់អង្គភាពនីមួយៗ នឹងត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ គ.ជ.អ.ប ។

មាត្រា ៨.-

អនុប្រធានលេខាធិការដ្ឋាន ប្រធាន អនុប្រធាន និងបុគ្គលិកតាមអង្គភាពនានានៃលេខាធិការដ្ឋាន ត្រូវជ្រើសរើសពីក្នុងចំណោមមន្ត្រីរដ្ឋបាលស៊ីវិលនៃក្រសួងមហាផ្ទៃ និងមន្ត្រីនៃក្រសួង ស្ថាប័នក្នុង គ.ជ.អ.ប ដែលមានចំណេះដឹង និងបទពិសោធន៍ការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ។

មន្ត្រីពីក្រសួង ស្ថាប័ននានាក្រៅពីក្រសួងមហាផ្ទៃ ដែលបានជ្រើសរើសឱ្យមកបំពេញការងារក្នុងលេខាធិការដ្ឋានក្រៅពីមុខតំណែងអនុប្រធានលេខាធិការដ្ឋាន និងប្រធាន អនុប្រធានអង្គភាពនៃលេខាធិការដ្ឋាន ត្រូវខិតខំលៃលកបំពេញការងារ យ៉ាងហោចណាស់ឱ្យបានពាក់កណ្តាលម៉ោងធ្វើការសម្រាប់ការងារលេខាធិការដ្ឋាន និងពាក់កណ្តាលម៉ោងទៀតត្រូវបំពេញការងារនៅក្រសួង ស្ថាប័នសាមី ។

គ.ជ.អ.ប ត្រូវចេញសេចក្តីសម្រេច ដើម្បីកំណត់អំពីលក្ខណៈវិនិច្ឆ័យសម្រាប់ការជ្រើសរើសមន្ត្រីពីក្រសួង ស្ថាប័ននានាមកបំពេញការងារក្នុងលេខាធិការដ្ឋាន ព្រមទាំងលក្ខខណ្ឌការងារសម្រាប់ការបំពេញការងារខាងលើនេះ ។

មាត្រា ៩.-

លេខាធិការដ្ឋានអាចធ្វើការជ្រើសរើសទីប្រឹក្សា ឬជំនាញការជាតិ ឬអន្តរជាតិ និងបុគ្គលិកជាប់កិច្ចសន្យា ដើម្បីជួយការងារលេខាធិការដ្ឋានតាមការចាំបាច់ ។

ទីប្រឹក្សា ឬជំនាញការជាតិ ឬអន្តរជាតិ និងបុគ្គលិកជាប់កិច្ចសន្យា មិនមែនជាបុគ្គលិករបស់លេខាធិការដ្ឋានឡើយ ។

គ.ជ.អ.ប ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ខ្លួន នូវតម្រូវការទីប្រឹក្សា ឬជំនាញការ និងបុគ្គលិកជាប់កិច្ចសន្យា លក្ខណៈវិនិច្ឆ័យនៃការជ្រើសរើស លក្ខខណ្ឌការងារសម្រាប់ទីប្រឹក្សា ឬជំនាញការ និងបុគ្គលិកជាប់កិច្ចសន្យាខាងលើនេះ ដោយឈរលើមូលដ្ឋាននៃប្រសិទ្ធភាពការងារ ។

## ជំពូកទី៤
## អំពីរបៀបរបបការងារ

មាត្រា ១០.-

ប្រធានលេខាធិការដ្ឋាន ត្រូវទទួលខុសត្រូវ និងមានគណនេយ្យភាពចំពោះ គ.ជ.អ.ប ចំពោះកិច្ចដំណើរការគ្រប់ផ្នែកទាំងអស់នៃលេខាធិការដ្ឋាន ។

មាត្រា ១១.-

ក្នុងការអនុវត្តការងារប្រចាំថ្ងៃ ដើម្បីអនុវត្តសេចក្តីសម្រេចរបស់ គ.ជ.អ.ប ក្នុងករណីមានភារកិច្ចដែលពាក់ព័ន្ធនឹងគោលនយោបាយ ឬការងារបន្ទាន់ចាំបាច់ណាមួយ ប្រធានលេខាធិការដ្ឋានត្រូវសុំយោបល់ដឹកនាំ ណែនាំដោយផ្ទាល់ពីប្រធាន គ.ជ.អ.ប ។

មាត្រា ១២.-

លេខាធិការដ្ឋាន ត្រូវសហការសម្របសម្រួលជាមួយអគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន នៃក្រសួងមហាផ្ទៃ ដើម្បីគាំទ្រដល់កិច្ចដំណើរការប្រចាំថ្ងៃរបស់លេខាធិការដ្ឋាន ។

គ.ជ.អ.ប អាចកំណត់ដោយសេចក្តីសម្រេចបន្ថែមទៀតនូវកិច្ចសហការសម្របសម្រួល និងទំនាក់ទំនងខាងលើនេះ ។

មាត្រា ១៣.–

ប្រធានលេខាធិការដ្ឋាន គឺជាប្រធានបុគ្គលិកទាំងអស់របស់លេខាធិការដ្ឋាន រួមទាំងអនុប្រធានលេខាធិការដ្ឋាន ប្រធាន អនុប្រធានអង្គភាពនៃលេខាធិការដ្ឋានផង ។

មាត្រា ១៤.–

អនុប្រធានលេខាធិការដ្ឋានត្រូវបំពេញការងារតាមការចាត់ចែងរបស់ប្រធានលេខាធិការដ្ឋាន ហើយត្រូវមានការទទួលខុសត្រូវ និងគណនេយ្យភាពចំពោះប្រធានលេខាធិការដ្ឋាន និងអាចជំនួសប្រធានលេខាធិការដ្ឋានតាមឋានានុក្រម ក្នុងពេលប្រធានលេខាធិការដ្ឋានអវត្តមាន ។

មាត្រា ១៥.–

ប្រធានអង្គភាពទាំងអស់ ត្រូវមានការទទួលខុសត្រូវ និងមានគណនេយ្យភាពចំពោះប្រធានលេខាធិការដ្ឋាន ។

មាត្រា ១៦.–

បុគ្គលិកតាមអង្គភាពនានានៃលេខាធិការដ្ឋាន ត្រូវមានការទទួលខុសត្រូវ និងគណនេយ្យភាពដោយផ្ទាល់ចំពោះប្រធានអង្គភាពរបស់ខ្លួន និងមានការទទួលខុសត្រូវ និងគណនេយ្យភាពដោយប្រយោលចំពោះប្រធានលេខាធិការដ្ឋាន ។

## ជំពូកទី៥
## អន្តរប្បញ្ញត្តិ

មាត្រា ១៧.–

ក្នុងពេលមិនទាន់រៀបចំបានលេខាធិការដ្ឋាន គ.ជ.អ.ប តាមគោលការណ៍នៃអនុក្រឹត្យនេះ លេខាធិការដ្ឋាននៃ គ.ជ.វ.វ ត្រូវធ្វើជាលេខាធិការដ្ឋានបណ្តោះអាសន្ននៃ គ.ជ.អ.ប ។

## ជំពូកទី៦
## អវសានប្បញ្ញត្តិ

មាត្រា ១៨.–

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ១៩.–

ប្រធានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័ន ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ មករា ឆ្នាំ ២០០៩

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

*កន្លែងទទួល* :

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
  *(ដើម្បីជូនជ្រាប)*
- *ដូចមាត្រា ១៩*
- *ឯកសារ កាលប្បវត្តិ*